ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ជម្ងឺសារទឹក



នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម *ASDP, ADB*
*Loan 2022-CAM(SF)*
ឆ្នាំ2010

# ជម្ងឺសារទឹក

Haemorrhagic Septicemia (HS) (Pasteurellosis)

## ១_និយមន័យៈ

ជំងឺសារទឹក ជាជំងឺឆ្លងរាតត្បាតយ៉ាងសាហាវមួយ ក្នុងចំណោមជំងឺឆ្លងនានា ។ បង្កឡើងដោយបាក់តេរីប៉ាស្ទ័ររ៉ែលឡាម៉ុលតូសីដា (Pasteurella Multocida ) បាក់តេរីនេះមានរាងជាកូនដំបងខ្លី គ្មានចលនា និងគ្មានស្ព័រ ។ កើតឡើងលើសត្វគ្រប់ប្រភេទដូចជាគោ–ក្របី ចៀម ពពែ ជ្រូក ។ល។ បណ្ដាលឱ្យមានការលាក និងដាំឈាមនៅតាមសរីរាង្គខាងក្នុងរបស់សត្វ ជាពិសេសប្រដាប់ដកដង្ហើម និងប្រដាប់រំលាយអាហារ ។ ជំងឺនេះច្រើនកើតមាននៅតំបន់ទំនាប សើមជោគជាំដក់ទឹក ពិសេសកើតមាននាដើមរដូវភ្លៀង ។ ជំងឺនេះបណ្ដាលឱ្យគោ–ក្របី ងាប់យ៉ាងឆាប់រហ័ស ។ សត្វដែលឆាប់ទទួលជំងឺនេះជាងគេ គឺក្របី ជាពិសេសចំពោះសត្វក្មេងអាចទទួលជំងឺនេះយ៉ាងឆាប់រហ័ស។

ជំងឺនេះកើតមានឡើងជារៀងរាល់ឆ្នាំនៅប្រទេសកម្ពុជា។ នៅឆ្នាំ២00៨ ជំងឺសារទឹកបានកើតនៅក្នុងខេត្តមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា

ក្នុងនោះមាន ខេត្តបាត់ដំបង ក្រចេះ បន្ទាយមានជ័យ កំពង់ចាម តាកែវ ព្រះសីហនុ កណ្ដាល សៀមរាប កំពង់ឆ្នាំង កំពត កំពង់ស្ពឺ កំពង់ធំ ស្វាយរៀង ព្រៃវែង កោះកុង រតនះគីរី ព្រះវិហារ កែប និងខេត្ត មណ្ឌលគីរី ។ សត្វកើតជំងឺមានចំនួនជាង ២0 000 ក្បាល ។

## ២_មូលហេតុ:

ជំងឺសារទឹកមានលក្ខណៈរាតត្បាតខ្លាំង ក្នុងកាលៈទេសៈដែលធាតុអាកាសប្រែប្រួល ហើយមិនស្របនឹងតម្រូវការបស់សត្វ ។ នៅពេលដែលសត្វមានសុខភាពចុះខ្សោយដោយសារប្រកាផ្សេងៗ ដូចជាការហេវហត់ ការប្រើសត្វហួសកម្លាំង ការផ្ដល់ចំណីមិនគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព ការផ្លាស់ប្ដូរចំណីអាហារ ការចាក់ថ្នាំការពារជំងឺដទៃទៀតសុទ្ធសឹងតែជាមូលហេតុបណ្ដាលឱ្យមេរោគនៃជំងឺសារទឹកឆក់ឱកាស។

## ៣_ការចម្លង និងការរាលដាលៈ

ជំងឺសារទឹកគោ–ក្របី ឆ្លងពីសត្វមួយទៅសត្វមួយទៀត តាមរយៈការប៉ះពាល់ផ្ទាល់ជាមួយសត្វឈឺ ឬ ភ្នាក់ងារផ្ទុកជំងឺ ការស៊ីស្មៅ ឬរុក្ខជាតិនៅលើកន្លែងដែលមានការផ្ទុះជំងឺ និងមិនផ្ទាល់ (ពពួកបា

រ៉ាស៊ីត) ។ ជាទូទៅសត្វគោ-ក្របី ដែលកើតជំងឺសារទឹកមានហូរទឹកមាត់ ទឹកសំបោរយ៉ាងច្រើន ដែលក្នុងនោះមានលាយឡំជាមួយបាក់តេរីប៉ាស្ទ័ររ៉ែលឡាផងដែរ ទៅលើបរិស្ថានជុំវិញកន្លែងដែលវារស់នៅលើវាលស្មៅ និងក្នុងទឹក ។ល។ ជាទូទៅជំងឺនេះអាចរាតត្បាតនិងកើតឡើងជាញឹកញាប់នៅពេលអាកាសធាតុប្រែប្រួល ជាពិសេសក្នុងរដូវភ្លៀងធ្លាក់ ។

## ៤_ រោគសញ្ញា:

- រយៈពេលមេរោគសម្ងំមានពី ២-៥ ថ្ងៃ
- សត្វអាចស្លាប់ក្នុងរយៈពេល ៦-២៤ ម៉ោង
- សត្វមានអាការៈគ្រុនក្តៅ សីតុណ្ហភាពឡើងខ្ពស់ កម្លាំងចុះខ្សោយ ចុះស្គមយ៉ាងឆាប់រហ័ស និងមានដំណោមនៅតាមស្រទាប់ភ្នាសស្តើងនៃសរីរាង្គខាងក្នុង ។ តាមធម្មតាសំគាល់ឃើញហើមនៅជុំវិញបំពង់ ក ហើយរាលដាលទៅដល់ចន្លោះជើងមុខ ឡើងទៅដល់ត្រចៀកនិងជួនកាលនៅជុំវិញក្បាលទៀតផង ។ អណ្តាតអាចឡើងហើមតឹងនិងលៀនចេញមកក្រៅ ភ្នែកឡើងហើម និងរលាកនៅតាមស្រទាប់ភ្នាសស្តើងត្របកភ្នែកក្នុង ។ សត្វហើមពោះ រាគឈាមលាយជាមួយរំអិលសំបោរ រលាកសួត ដកដង្ហើមដង្ហក់ ដើរញាប់ ។



ការហើមមុខ ក្បាល និង ក



ស្នាមជាំឈាមខ្មៅនៅលើ និងក្នុងសួតសត្វ



ស្នាមជាំឈាមស្រទាប់ភ្នាសសាច់ខាងក្នុងមាត់ និងស្រទាប់ភ្នាសសាច់ខាងក្នុងនៃ ក

## ៥. វិធានការការពារ:

### ក- វិធានការទប់ស្កាត់:

មានសុភាសិតខ្មែរមួយឃ្លាបាននិយាយថា"ការពារប្រសើរជាងការព្យាបាល" ដូចនេះដើម្បីការពារសត្វកុំឱ្យកើតជម្ងឺសារទឹកក៏ដូចជាជម្ងឺឆ្លងផ្សេងៗអ្នកចិញ្ចឹមសត្វត្រូវអនុវត្តឱ្យបានល្អនូវវិធានជីវសុវត្ថិភាពក្នុងការចិញ្ចឹមសត្វគោ-ក្របី ដោយៈ

- ត្រូវធ្វើអនាម័យក្រោលសត្វឱ្យបានស្អាតជានិច្ច
- ត្រូវឧស្សាហ៍ពិនិត្យគុណភាពចំណី និងតាមដានឃ្លាំមើលសុខភាពសត្វ
- ត្រូវផ្តល់ចំណី និងទឹកឱ្យបានគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព
- វិធានការដែលមានប្រសិទ្ធភាព ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺសារទឹកគឺ ត្រូវចាក់វ៉ាក់សាំងការពារ ជម្ងឺសារទឹកឱ្យសត្វឱ្យបានទៀងទាត់តាមប្រតិទិនចាក់ថ្នាំការពារ ជាពិសេសចំពោះសត្វគោ-ក្របី ដែលមានអាយុក្រោម ៣ ឆ្នាំ ព្រោះសត្វជិទង់ៗងាយឆ្លងជម្ងឺនេះណាស់ ។ វ៉ាក់សាំងការពារជម្ងឺសារទឹកផ្តល់ភាពស៊ាំបានរយៈពេល ៦ ខែ ចំពោះថ្នាំប្រភេទរាវ និង១២ខែចំពោះប្រភេទខាប់ ។ ភាពស៊ាំមានរយៈពេល ៥-៧ ថ្ងៃក្រោយពីការចាក់ថ្នាំការពារជម្ងឺ ។

ត្រូវចាក់ថ្នាំការពារ ១ ឆ្នាំ ២ ដង មុនរដូវភ្លៀងធ្លាក់ក្នុងខែ ៤-៥ និង មុនរដូវក្តៅខែ ១០ ឬ ខែ ១១។




ថ្នាំការពារសត្វសំរាប់ប្រឆាំងនឹងជំងឺសារទឹកគោ-ក្របី

**ខ-វិធានការទប់ស្កាត់ជំងឺឆ្លងនៅក្នុងតំបន់កំពុងកើតជំងឺ:**

ក្នុងករណីមានកើតជំងឺឬសង្ស័យថាមានសត្វឈឺជំងឺសារទឹកម្ចាស់សត្វ ឬម្ចាស់កសិដ្ឋានត្រូវប្រញាប់រាយការណ៍ ជូនមន្ត្រីបសុពេទ្យ ឬ ភ្នាក់ងារសុខភាពសត្វភូមិដែលនៅជិតបំផុត ។ ធ្វើការកាត់ផ្តាច់ទំនាក់ទំនងរវាងសត្វឈឺ និងសត្វជា និងសត្វដែលសង្ស័យថាមានជំងឺ ។ មន្ត្រីផលិតកម្ម និងបសុព្យាបាលក្រោយពីបានទទួលដំណឹងភ្លាមចាំបាច់ត្រូវផ្សព្វផ្សាយជាបន្ទាន់ដល់អាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ និងអង្គភាពជំនាញវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ដើម្បី

រួមគ្នាធ្វើការកំចាត់ដោយឈានទៅអនុវត្តនូវវិធានការដូចខាងក្រោមៈ

- បំបែកសត្វឈឺចេញពីហ្វូង
- កំណត់តំបន់រាតត្បាតនៃជម្ងឺឆ្លង
- រៀបចំកំណត់ព្រំដែនធ្វើចត្តាឡីស័ក្តនៅតំបន់កើតជម្ងឺឆ្លង និង តំបន់ទទួលការគំរាមកំហែង
- រៀបចំចាក់ថ្នាំការពារដល់សត្វដែលមិនទាន់ឈឺ
- ផ្សព្វផ្សាយពីប្រភពចម្លងរោគ និងរបៀបចម្លងរោគដល់ប្រជាកសិករឱ្យគេយល់ច្បាស់ និងជាពិសេសដល់អាជ្ញាធរដែនដីគ្រប់មូលដ្ឋានដើម្បីសហការកំចាត់ជម្ងឺឆ្លង
- បញ្ជូនវត្ថុវិភាគទៅមន្ទីរពិសោធន៍
- ជៀសវាងការផ្តល់ចំណីដូចជាស្មៅរុក្ខជាតិមានប្រភពពីកន្លែងកើតជំងឺ ឬឆ្លងជំងឺ
- ហាមចលនាសត្វចេញ-ចូល ឬឆ្លងកាត់តំបន់កើតជំងឺ
- ហាមទិញ-លក់សត្វគ្រប់ប្រភេទដែលមានជំងឺ ឬផ្ទុកមេរោគ
- ហាមប៉ះពាល់សត្វងាប់ និងពិឃាតសត្វឈឺ ឬសត្វដែលសង្ស័យថាឈឺ យកសាច់លក់ ឬបរិភោគ
- ដកចំណីអាហារដែលដាក់ឱ្យសត្វឈឺស៊ី ឬក្រាលឱ្យវាដេកដុតកំទេចចោល

- កន្លែងសត្វឈើ កន្លែងទុកដាក់សម្ភារៈផ្សេងៗត្រូវធ្វើការរំងាប់មេរោគ
- វិធានការចត្តាលីស័ក្កត្រូវបានដកចេញវិញ ៣០ ថ្ងៃ ក្រោយពីបានពិនិត្យឃើញថា សត្វទាំងអស់បានជាសះស្បើយឡើងវិញដោយភ្នាក់ងារបសុពេទ្យ ។

ឯកសារយោង:


- របាយការណ៍បូកសរុបលទ្ធផលការងារផលិតកម្ម និងបសុព្យាបាល ប្រចាំឆ្នាំ ២០០៦- ២០០៧ , ឆ្នាំ ២០០៧-២០០៨ របស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
- យុទ្ធសាស្ត្រអភិវឌ្ឍវិស័យចិញ្ចឹមសត្វនៅកម្ពុជាដោយវិទ្យាស្ថានជីវសាស្ត្រវេជ្ជសាស្ត្រ និងកសិកម្ម រាជបណ្ឌិត សភា ឆ្នាំ ២០០៨
- បទបង្ហាញ ស្ដីពី ការយកវត្ថុវិភាគរបស់លោកស្រី វ៉េន ធារី មន្ត្រីវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល, នាយកដ្ឋាន ផលិតកម្ម និងបសុព្យាបាលថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩
- បទបង្ហាញស្ដីពីការពង្រឹងលើការអនុវត្តលិខិតបទដ្ឋាននៃអនុក្រឹតលេខ ២៦ អនក្រ.បកចុះថ្ងៃទី ០២ មីនា ឆ្នាំ ២០០១ ស្ដីពីការបង្កើត និងគ្រប់គ្រងភ្នាក់ងារសុខភាពសត្វភូមិ របស់លោកពេច ប៉េដា (២៤/០៣/០៩)
- ខិតប័ណ្ណស្ដីពីអត្ថប្រយោជន៍នៃការចាក់ថ្នាំការពារជំងឺសារទឹក របស់នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ។







ការផ្សាយរបស់ក្រុមការងារផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម
កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម *ASDP, ADB*

*Loan 2022-CAM{SF}*

ឆ្នាំ 2010